**ស្វាគមន៍ មកកាន់ការផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិចវ៉ាស៊ីនតោន (EBT) និងកាត Quest EBT វ៉ាស៊ីនតោន - វិធីសុវត្ថិភាព ងាយស្រួល និងស្រណុកក្នុងការប្រើអត្ថប្រយោជន៍របស់អ្នក.**

ប្រសិនបើអ្នកមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សម្រាប់អត្ថប្រយោជន៍អាហារមូលដ្ឋាន អ្នកអាចប្រើកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នកដើម្បីទិញម្ហូបអាហារដែលមានសិទ្ធិនៅតាមហាងដែលចូលរួមណាមួយ រួមទាំងហាងដែលផ្តល់ការជាវលើបណ្តាញ។

ប្រសិនបើអ្នកមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សម្រាប់អត្ថប្រយោជន៍ជាសាច់ប្រាក់ អ្នកអាចប្រើអ្នកអាចប្រើកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នកដើម្បីទទួលសាច់ប្រាក់ ឬបង់ថ្លៃជាវហាងដែលចូលរួម និងដកអត្ថប្រយោជន៍របស់អ្នកនៅ ATMs ។

## វាសាមញ្ញណាស់!



### របៀបប្រើកាត QUEST EBT វ៉ាស៊ីនតោនរបស់អ្នកនៅតាមហាង

1. ដឹងពីសមតុល្យរបស់អ្នកមុនពេលអ្នកទៅទិញទំនិញដោយចូលទៅ www.ebtedge.com ឬទូរសព្ទទៅសេវាអតិថិជន។
2.ឆូតកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នកតាមបញ្ឆរម៉ាស៊ីនឆូតកាតគិតប្រាក់ (POS) ឬប្រគល់កាតរបស់អ្នកទៅអ្នកលក់/អ្នកគិតលុយ។
3. ត្រូវប្រាកដថាប្រាប់អ្នកលក់ថាគិតប្រាក់ពីគណនីមួយណា (អាហារ ឬសាច់ប្រាក់)។
4. បញ្ចូលលេខសម្គាល់ផ្ទាល់ខ្លួនបួនខ្ទង់ (ភីណ) លើគ្រាប់ចុច។ ឌីមីទល នឹងបង្ហាញ****។
5. ចុច OK ឬយី ENTER ។
6. អ្នកលក់បញ្ចូលចំនួនជាវ ហើយប្រសិនបើវាត្រឹមត្រូវហើយ អ្នកចុចយី YES ។
7. អ្នកលក់នឹងប្រគល់វិក្កយបត្រឱ្យអ្នក។ ត្រូវប្រាកដថាព័ត៌មាននៅលើវិក្កយបត្រត្រឹមត្រូវ។
8. រក្សាវិក្កយបត្រនេះ ដូច្នេះអ្នកនឹងដឹងពីសមតុល្យថ្មីរបស់អ្នក នៅពេលអ្នកទិញទំនិញពេលបន្ទាប់។

ជំហានទីមួយៗអាចខុសគ្នាទៅតាមប្រភេទម៉ាស៊ីន POS ឬប្រព័ន្ធទូទាត់ចេញទីមួយៗ ដែលអ្នកប្រើ។ សួរអ្នកលក់បើអ្នកត្រូវការជំនួយ។

មានតែចំនួនបន្ថែមនៃការជាវអាហាររបស់អ្នកប៉ុណ្ណោះត្រូវបានកាត់ពីគណនីអត្ថប្រយោជន៍អាហាររបស់អ្នក។ ហាងនឹងមិនឱ្យលុយអាប់សម្រាប់ការជាវអត្ថប្រយោជន៍អាហារនោះទេ។

អ្នកអាចប្រើអត្ថប្រយោជន៍ជាសាច់របស់អ្នកនៅហាងដើម្បីដកតែសាច់ប្រាក់ ឬដើម្បីជាវទាំងអាហារ និងរបស់ដែលមិនមែនជាអាហារ (សាប៊ូ កន្ទបទារក)។ ហាងក៏អាច ផ្តល់សាច់ប្រាក់ត្រលប់នៅពេលអ្នកធ្វើការជាវពីគណនីជាសាច់ប្រាក់របស់អ្នក។ ប្រសិនបើអ្នកមានសំណួរ សួរអ្នកលក់។




### របៀបប្រើកាត QUEST EBT វ៉ាស៊ីនតោនរបស់អ្នកតាមម៉ាស៊ីនបញ្ឆោដកប្រាក់ដោយស្វ័យប្រវត្តិ (ATM)

(សម្រាប់ការដកអត្ថប្រយោជន៍សាច់ប្រាក់តែប៉ុណ្ណោះ អត្ថប្រយោជន៍អាហារមិនអាចចូលប្រើតាម ATM ទេ)

1. បញ្ចូល ឬឆូតកាតរបស់អ្នក។
2. បញ្ចូល ភីណ របស់អ្នក ហើយចុចយី OK ឬ ENTER ។
3. ជ្រើសរើសយីដែលសម្គាល់ថា WITHDRAW CASH ហើយបន្ទាប់មកជ្រើសរើស CHECKING
4. បញ្ចូលចំនួនដែលអ្នកចង់ក្នុងចំនួនដុល្លារទាំងអស់ ឧទាហរណ៍ $20, $40, $60, ជាដើម។
5. ប្រសិនបើមានគិតថ្លៃបន្ថែម ៖
   - ជ្រើសរើស YES ដើម្បីទទួលវា ហើយបន្តជាមួយប្រតិបត្តិការ។
   - ជ្រើសរើស NO ដើម្បីបោះបង់ប្រតិបត្តិការប្រសិនបើអ្នកមិនចង់បង់ថ្លៃបន្ថែម។
6. យកកាតរបស់អ្នក បង្កាន់ដៃរបស់អ្នក សាច់ប្រាក់របស់អ្នក។ ប្រសិនបើ ATM លេបកាតរបស់អ្នក ទាក់ទងសេវាអតិថិជននៅលេខ 888-328-9271។
7. រាប់សាច់ប្រាក់របស់អ្នក ហើយប្រៀបធៀបវាទៅនឹងបង្កាន់ដៃរបស់អ្នក។
8. បង្កាន់ដៃ ATM នឹងបង្ហាញសមតុល្យសាច់ប្រាក់នៅតែអាចប្រើបាន។

វាអាចត្រូវការប្រតិបត្តិការជាច្រើនដើម្បីដកអត្ថប្រយោជន៍សាច់ប្រាក់របស់អ្នកទាំងអស់ពី។ទំ ប្រសិនបើម៉ាស៊ីនមានកំណត់លើចំនួនសាច់ប្រាក់ដែលអ្នកអាចដកបានរាល់ដង។ វាអាចគិតថ្លៃបន្ថែមដោយ ATM សម្រាប់ប្រតិបត្តិការទីមួយៗ។

## សំណួរ និងចម្លើយ QUEST EBT វ៉ាស៊ីនតោន

### *តើខ្ញុំទទួលអត្ថប្រយោជន៍ជាមួយកាត Quest EBT វ៉ាស៊ីនតោនយ៉ាងដូចម្តេច?*

រាល់ខែអត្ថប្រយោជន៍របស់អ្នកនឹងត្រូវបានបន្ថែមដោយស្វ័យប្រវត្តិទៅកាន់គណនីរបស់អ្នក។ អ្នកនឹងប្រើ កាត Quest EBT វ៉ាស៊ីនតោនដដែលរាល់ខែដើម្បីទទួលអត្ថប្រយោជន៍របស់អ្នក។ ដូចដែលអ្នកប្រើអត្ថប្រយោជន៍របស់អ្នកដើម្បីទទួលសាច់ប្រាក់ ឬទិញទំនិញ សមតុល្យគណនីរបស់អ្នកនឹងថយចុះ។ មិនចាំបាច់ត្រូវប្តូរកាតរបស់អ្នកទេ លុះត្រាតែវាបាត់ លួច ឬខូច។

### *តើខ្ញុំទទួលបានអត្ថប្រយោជន៍របស់ខ្ញុំនៅពេលណា?*

អត្ថប្រយោជន៍នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនី EBT របស់អ្នកនៅថ្ងៃដូចគ្នារាល់ខែ បើទោះបីជាវាចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃសម្រាកក៏ដោយ។ អត្ថប្រយោជន៍ទាំងអស់គឺអាចរកបាននៅម៉ោង 9 ព្រឹក ម៉ោងប៉ាស៊ីហ្វិក។ អត្ថប្រយោជន៍ណាមួយដែលអ្នកនៅសល់ដល់ចុងខែនឹងនៅបន្តទៅខែបន្ទាប់។

### *តើខ្ញុំអាចប្រើកាត **Quest EBT** វ៉ាស៊ីនតោនរបស់ខ្ញុំនៅកន្លែងណាខ្លះ?*

អ្នកអាចប្រើកាត Quest EBT វ៉ាស៊ីនតោននៅហាងដែលចូលរួម និង ATMs (សម្រាប់អត្ថប្រយោជន៍ជាសាច់ប្រាក់តែប៉ុណ្ណោះ) ឆ្លងប្រទេស។ អ្នកក៏អាចប្រើកាតរបស់អ្នកនៅពេលណាដែលអ្នកឃើញស្លាកសញ្ញា ឈុសេត ។ ប្រសិនបើមិនឃើញស្លាកសញ្ញា Quest ទេ សួរអ្នកគ្រប់គ្រងហាងថាតើអ្នកអាចប្រើកាតរបស់អ្នកក្នុងហាងដើម្បីទិញអាហារ ឬទទួលជាសាច់ប្រាក់ឬទេ។

### *តើខ្ញុំគួរធ្វើអ្វីបើខ្ញុំបាត់កាតរបស់ខ្ញុំ?*

ប្រសិនបើកាត Quest EBT វ៉ាស៊ីនតោនរបស់បាត់ លួច ឬខូច អ្នកគួរតែទូរសព្ទទៅសេវាអតិថិជនភ្លាមៗ ខ្សែមិនគិតថ្លៃនៅលេខ 888-328-9271 ដើម្បីបិទសកម្មភាព ហើយកាតប្តូរថ្មីនឹងផ្ញើទៅអ្នក។

### *តើលេខកាតរបស់ខ្ញុំគឺអ្វីខ្លះ?*

លេខកាតរបស់អ្នកគឺលេខ 16 ខ្ទង់ ដែលមានបោះពុម្ពលើកាត។

### *ចុះបើកាតរបស់ខ្ញុំមិនដំណើរការ?*

ទូរសព្ទទៅសេវាអតិថិជន ហើយពួកគេនឹងជួយអ្នក។ លេខខ្សែមិនគិតថ្លៃរកមើលនៅខ្នងកាតរបស់អ្នក។ សេវាអតិថិជនគឺអាចរកបាន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។

### *ចុះបើមានប្រតិបត្តិការមិនត្រឹមត្រូវលើគណនីរបស់ខ្ញុំ?*

នៅពេលដែលបង់ប្រាក់ច្រើន ឬតិចពេកដល់អ្នកលក់រាយពីគណនី EBT របស់អ្នក ដោយសារតែបញ្ហាប្រព័ន្ធកុំព្យូទ័រ ការកែអាចធ្វើឡើងចំពោះសមតុល្យរបស់អ្នក។ ការកែអាចប៉ះពាល់សមតុល្យខែនេះ ឬខែក្រោយរបស់អ្នក។ អ្នកនឹងផ្ញើការជូនដំណឹងការលៃតម្រូវ EBT នៃការកែបើវាកាត់សមតុល្យរបស់អ្នក។

### *តើខ្ញុំថែទាំកាតរបស់ខ្ញុំយ៉ាងដូចម្តេច?*

1. ចុះហត្ថលេខានៅខ្នងកាតរបស់អ្នក។
2. កុំសរសេរ ភីណ របស់អ្នកលើកាតរបស់អ្នក។
3. ទុកកាតរបស់អ្នកឱ្យមានសុវតិភាព និងនៅស្អាត។
4. កុំពត់កាតរបស់អ្នក។
5. ទុកកាតរបស់អ្នកឆ្ងាតពីមេដែក និងឧបករណ៍អេឡិចត្រូនិច ដូចជាទូរទស្សន៍ មីក្រូវើវជាដើម។
6. កុំដាក់វាក្នុងកន្លែងត្រូវពន្លឺព្រះអាទិត្យដោយផ្ទាល់ ដូចជាផ្ទាំងគ្រប់គ្រងរថយន្តរបស់អ្នក។
7. កុំចោលកាតរបស់អ្នក អ្នកប្រើកាតដដែលនេះរាល់ខែដរាបណាអ្នកទទួលបានអត្ថប្រយោជន៍។
8. ការប្តូរកាតច្រើនដងពេកអាចក្លាយជាការស៊ើបអង្កេតចំពោះការប្រើក្លែងបន្លំ។

### *តើលេខសម្គាល់ផ្ទាល់ខ្លួនគឺជាអ្វី?*

PIN គឺជាលេខសម្ងាត់បួនខ្ទង់ដែលអនុញ្ញាតឱ្យតែអ្នកប៉ុណ្ណោះប្រើកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នក។ កាត EBT មិនដំណើរការដោយគ្មាន PIN ទេ។ កុំប្រាប់ PIN របស់អ្នកទៅនរណាម្នាក់ ពួកគេអាចប្រើកាតរបស់អ្នកដើម្បីយកអត្ថប្រយោជន៍របស់អ្នកទាំងអស់ ហើយអត្ថប្រយោជន៍ទាំងនោះនឹងមិនត្រូវបានជំនួសឡើយ។

### *តើខ្ញុំជ្រើសរើស **PIN** យ៉ាងដូចម្តេច?*

អ្នកអាចជ្រើសរើស PIN បួនខ្ទង់ដោយទូរសព្ទទៅសេវាអតិថិជន ឬមកជួបនៅការិយាល័យសេវាសហគមន៍ (CSO) DSHS ក្នុងតំបន់របស់អ្នក។ កុំប្រើ PIN ងាយស្រួលទាយដូចជា “1234, ឬ “0000” ឬគំនូរងាយស្រួលទាយ។

### *ចុះបើខ្ញុំភ្លេច **PIN** របស់ខ្ញុំ?*

ប្រសិនបើអ្នកភ្លេច PIN របស់អ្នក ឬចង់ផ្លាស់ប្តូរ PIN របស់អ្នក អ្នកអាចទូរសព្ទទៅសេវាអតិថិជន។

### *ចុះបើខ្ញុំបញ្ចូល **PIN** ខុស?*

ប្រសិនបើអ្នកបញ្ចូល PIN ខុស អ្នកមានឱកាសបីដងទៀតដើម្បីបញ្ចូលលេខ។ ប្រសិនបើមិនបានបញ្ចូល PIN ត្រឹមត្រូវនៅពេលព្យាយាមលើកទីបួនទេ កាតនឹងត្រូវចាក់សោដើម្បីការពារគណនីរបស់អ្នក អ្នកនឹងមិនអាចប្រើកាតរបស់ម្តងទៀតឡើយរហូតដល់ផុតពាក់កណ្តាលយប់ លុះត្រាតែទៅកាន់ការិយាល័យសេវាសហគមន៍ DSHS ក្នុងតំបន់ដើម្បីសោ។ ក្នុងករណីមួយចំនួន កាតរបស់អ្នកអាចលេបដោយ ATM។ ប្រសិនបើ ATM លេបកាតរបស់អ្នក ទាក់ទងសេវាអតិថិជន។

### *តើខ្ញុំគួរធ្វើអ្វីបើនរណាម្នាក់ស្គាល់ **PIN** របស់ខ្ញុំ?*

ជ្រើសរើស ភីណ ថ្មីមួយភ្លាមដោយទូរសព្ទទៅសេវាអតិថិជន ឬដោយផ្លាស់ប្តូរ PIN របស់អ្នកលើបណ្តាញនៅ **www.ebtedge.com** ឬកម្មវិធីចល័ត *ebt*EDGE។

### *តើខ្ញុំដឹងពីសមតុល្យរបស់ខ្ញុំយ៉ាងដូចម្តេច?*

វិធីដែលងាយបំផុតដើម្បីដឹងពីសមតុល្យគណនីរបស់អ្នកគឺរក្សាបង្កាន់ដៃរបស់អ្នក។ ប្រសិនបើអ្នកមិនមានបង្កាន់របស់អ្នក អ្នកអាចពិនិត្យសមតុល្យរបស់អ្នកនៅ **www.ebtedge.com** ឬ កម្មវិធីចល័ត បេតខែង ឬអ្នកអាចទូរសព្ទទៅសេវាអតិថិជន។ អ្នកគួរតែដឹងពីសមតុល្យគណនីរបស់អ្នកជានិច្ចមុនពេលអ្នកទិញទំនិញ។

## តើមានអ្វីកើតឡើងបើម៉ាស៊ីនឆូតកាតគិតប្រាក់ (POS) មិនដំណើរការ?

ប្រសិនបើអ្នកចង់ជាវអាហារដែលមានសិទ្ធិជាមួយអត្ថប្រយោជន៍របស់អ្នក ហើយម៉ាស៊ីន POS មិនដំណើរការ ឬមិនមាននៅហាង អ្នកគិតលុយនឹងបំពេញបែបទម្រង់ជាសហោថាប័ណ្ណមានទឹកប្រាក់អត្ថប្រយោជន៍។ អ្នកគិតលុយនឹងសរសេរក្នុងលេខកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នក និងចំនួនដែលអ្នកកំពុងចំណាយ។ កុំផ្តល់ PIN របស់អ្នកទៅអ្នកគិតលុយ។ អ្នកគិតលុយនឹងទូរសព្ទដើម្បីដឹងថាតើអ្នកមានអត្ថប្រយោជន៍គ្រប់គ្រាន់ឬទេ ក្នុងគណនីអត្ថប្រយោជន៍អាហាររបស់អ្នកដើម្បីទិញអាហារ ពួកគេនឹងមិនពិនិត្យគណនីអត្ថប្រយោជន៍សាច់ប្រាក់របស់អ្នកទេ។ ប្រសិនបើមានគ្រប់គ្រាន់នៅក្នុងគណនីអត្ថប្រយោជន៍អាហាររបស់អ្នក អ្នកនឹងត្រូវស្នើឱ្យចុះហត្ថលេខាលើប័ណ្ណមានទឹកប្រាក់ ហើយអ្នកនឹងត្រូវផ្តល់ច្បាប់ចម្លង។ វាចាំបាច់ត្រូវរក្សាច្បាប់ចម្លងនេះ ដូច្នេះអ្នកអាចដកយកអ្វីដែលអ្នកបានចំណាយពីសមតុល្យដែលបានបង្ហាញលើបង្កាន់ដៃ EBT ចុងក្រោយរបស់អ្នក។ នេះនឹងផ្តល់ឱ្យអ្នកនូវចំនួនបច្ចុប្បន្នលើគណនីរបស់អ្នក។ ហាងមិនអាចដំណើរការប័ណ្ណមានទឹកប្រាក់ដោយដៃទេសម្រាប់អត្ថប្រយោជន៍ជាសាច់ប្រាក់។

## តើខ្ញុំអាចទៅកាន់បេឡាករធនាគារ ហើយដកប្រាក់ ឬសួរអំពីគណនី EBT របស់ខ្ញុំបានឬទេ?

ទេ អ្នកអាចតែដកសាច់ប្រាក់ពី ATM ឬតាមរយៈម៉ាស៊ីន POS ដែលផ្តល់សាច់ប្រាក់ត្រលប់នៅហាងដែលចូលរួម។ ប្រសិនបើអ្នកមានសំណួរអំពីគណនីសាច់ប្រាក់ ឬអាហាររបស់អ្នក ទូរសព្ទទៅសេវាអតិថិជន។

## ប្រសិនបើខ្ញុំមានតិចជាង $10 ´នអត្ថប្រយោជន៍សាច់ប្រាក់លើកាត Quest EBT វ៉ាស៊ីនតោនរបស់ខ្ញុំ តើទទួលបានយ៉ាងដូចម្តេច?

អ្នកអាចធ្វើការជាងម៉ាស៊ីន POS ឬប្រតិបត្តិការសាច់ប្រាក់ត្រលប់នៅហាងដែលចូលរួមដើម្បីទទួលប្រាក់ទាំងនេះ។

## តើមានថ្លៃសេវាប្រតិបត្តិការណាមួយ ឬការគិតថ្លៃបន្ថែមសម្រាប់ការប្រើកាត Quest EBT វ៉ាស៊ីនតោនរបស់ខ្ញុំ?

មិនមានថ្លៃសេវាប្រតិបត្តិការទេសម្រាប់ការប្រើអត្ថប្រយោជន៍អាហាររបស់អ្នកដើម្បីទិញអាហារជាមួយកាត Quest EBT វ៉ាស៊ីនតោនរបស់អ្នក។ ក៏មិនមានថ្លៃសេវាប្រតិបត្តិការសម្រាប់ការអត្ថប្រយោជន៍ជាសាច់ប្រាក់ដើម្បីទិញអាហារ ឬទទួលប្រាក់នៅម៉ាស៊ីន POS ដែរ។

អាចមានការគិតថ្លៃបន្ថែម។ ការគិតថ្លៃបន្ថែមគឺជាថ្លៃសេវាបន្ថែមដែលគិតដោយម្ចាស់ ATM ឬម៉ាស៊ីន POS សម្រាប់ការប្រើម៉ាស៊ីននោះក្នុងការដកប្រាក់។ ការគិតថ្លៃបន្ថែម បើមាន ក៏នឹងយកពីគណនីសាច់ប្រាក់របស់អ្នកដោយស្វ័យប្រវត្តិ។ ប្រសិនបើអ្នកមិនចង់ចំណាយការគិតថ្លៃបន្ថែម គ្រាន់តែបោះបង់ប្រតិបត្តិការរបស់អ្នក ហើយទៅកាន់ ATM ឬទីតាំង POS មួយផ្សេងដែលមិនគិតថ្លៃបន្ថែម។

## តើមានការដាក់កំហិតលើរបៀបដែលខ្ញុំប្រើអត្ថប្រយោជន៍សាច់ប្រាក់ EBT របស់ខ្ញុំឬទេ?

វាប្រឆាំងនឹងច្បាប់ក្នុងការប្រើកាត EBT ឬសាច់ប្រាក់ពីកាត EBT នៅតៀមស្រាបារ ហាងស្រា ភ្នាក់ងារប្រាក់ធានា កន្លែងកម្សាន្តមនុស្សពេញវ័យ និងកន្លែងផ្សេងទៀតដែលហាមឃាត់អនីតិជន ល្បែង ចាក់សាក់ ឬការចោះសាច់ ឬជាវថ្នាំជក់ កញ្ឆា ឬផលិតផលកញ្ឆា។

## តើមានអ្វីកើតឡើងបើខ្ញុំមិនប្រើអត្ថប្រយោជន៍របស់ខ្ញុំ?

អត្ថប្រយោជន៍មិនត្រូវបានប្រើអំឡុងពេលខែចេញ នឹងបន្តទៅខែបន្ទាប់។ ប្រសិនបើអ្នកមិនចង់ប្រើយ៉ាងហោចណាស់អត្ថប្រយោជន៍មួយចំនួនក្នុងពេល 274 ថ្ងៃ អត្ថប្រយោជន៍នឹងត្រូវលុបចោល។ ក្នុងករណីមួយចំនួន អត្ថប្រយោជន៍ទាំងនេះនឹងត្រូវជំនួស។

## តើខ្ញុំអាចដាក់ប្រាក់ចូលគណនី EBT របស់ខ្ញុំឬទេ?

ទេ។ អ្នកអាចតែដកប្រាក់ពីគណនីសាច់ប្រាក់របស់អ្នកប៉ុណ្ណោះ។

## តើការដាក់ប្រាក់ដោយផ្ទាល់គឺជាអ្វី?

ជំនួយឱ្យការប្រើ EBT អ្នកអាចជ្រើសរើសដាក់ប្រាក់ចូលអត្ថប្រយោជន៍ជាសាច់ប្រាក់របស់អ្នករាល់ខែដោយផ្ទាល់ទៅក្នុងគណនីធនាគាររបស់អ្នក។ ទាក់ទង DSHS សម្រាប់ព័ត៌មានបន្ថែម ឬទូរសព្ទទៅខ្សែមិនគិតថ្លៃនៅលេខ 888-235-2954.

## តើម្ចាស់កាតជំនួសគឺជាអ្វី?

អ្នកអាចជ្រើសរើមនុស្សម្នាក់ ដែលហៅជាម្ចាស់កាតជំនួស ដើម្បីចូលប្រើអត្ថប្រយោជន៍របស់អ្នក។ ម្ចាស់កាតជំនួសត្រូវតែទៅកាន់ការិយាល័យក្នុងតំបន់ដើម្បីទទួលបានកាត Quest EBT វ៉ាស៊ីនតោន និង PIN។ ប្រសិនបើអ្នកត្រូវការម្ចាស់កាតជំនួស ជ្រើសរើសមនុស្សដែលអ្នកទុកចិត្ត។ ចងចាំថា អត្ថប្រយោជន៍ដែលបានលួច បាត់នឹងមិនត្រូវជំនួសទេ។ អ្នកអាចបោះបង់កាតម្ចាស់ជំនួសបានដោយទូរសព្ទទៅសេវាអតិថិជន។

## តើខ្ញុំទូរសព្ទទៅសេវាអតិថិជននៅពេលណា?

- ប្រសិនបើកាតរបស់អ្នកបាត់ លួច ឬខូច។
- ប្រសិនបើភ្លេច ឬបាត់ ភីណ របស់អ្នក។
- ដើម្បីជ្រើសរើស ឬផ្លាស់ប្តូរ PIN របស់អ្នក។
- ដើម្បីដឹងពីសមតុល្យរបស់អ្នក។
- ដើម្បីឮពីប្រតិបត្តិការ ១០ ដង ចុងក្រោយរបស់អ្នក
- ដើម្បីស្នើសុំប្រវត្តិប្រតិបត្តិការពីរខែ។
- ប្រសិនបើអ្នកមានសំណួរអំពីប្រតិបត្តិការ។
- ប្រសិនបើអ្នកមានសំណួរ ឬត្រូវការជំនួយជាមួយកាតរបស់អ្នក។

## ចុះបើខ្ញុំគ្រោងផ្លាស់ទី ឬផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្ញុំ?

ដើម្បីរាយការណ៍ការផ្លាស់ប្តូរណាមួយ រួមទាំងការអាប់ដេតអាសយដ្ឋានរបស់អ្នក ឌសិះសិ ទាក់ទង ដោយទូរសព្ទទៅលេខ ៨៧៧-៥០១-២២៣៣ ឬប្រើ **www.washingtonconnection.org** ដើម្បីរាយការណ៍ការផ្លាស់ប្តូរលើបណ្តាញ។

This pamphlet is available in your language at your local DSHS Office.

ይህ አስተኛ መጽሔት በቋንቋዎ በአካባቢዎ የዲኤስኤችኤስ ጽህፈት ቤት ይገኛል። (Amharic)

إن هذه النسخة موفرة لك بلغتك في مكتب الـ DSHS في الضاحية التي تسكن بها. (Arabic)

កូនសៀវភៅនេះមានផ្តល់ជូនជាភាសាររបស់លោកអ្នកនៅនឹងការិយាល័យ DSHS ប្រចាំតំបន់របស់លោកអ្នក ។ (Cambodian)

本小冊備有您的語言版本，可向您當地的 DSHS 辦事處索取。(Chinese)

اين جزوه در زبان شما در اداره خدمات اجتماعي و درماني DSHS منطقه ايتان در دسترس مي باشد. (Farsi)

Dlaim ntawv nuav muaj txhais ua koj yaam lug hab nwg nyob rua ntawm lub DSHS kws ze koj ko. (Hmong)

이 팜플렛의 한국어 팜플렛은 귀하지역 관할 보건사회부(DSHS) 사무소에 비치돼 있습니다.(Korean)

ປື້ມຄູ່ມືຫົວນີ້ມີໃວ້ໃຫ້ໃນພາສາຂອງທ່ານຢູ່ທີ່ຫ້ອງການ DSHS ທ້ອງຖິ່ນຂອງທ່ານ. (Laotian)

ਇਹ ਪੈਂਫਲੇਟ ਤੁਹਾਨੂੰ ਮਿਲ ਸਕਦਾਂ ਹੈ ਆਪ ਦੀ ਭਾਸ਼ਾ ਵਿਚੱ ਆਪਣੇ ਸਥਾਨੀ DSHS ਦਫਤਰ ॥ (Punjabi)

Acest pamflet este disponibil în limba dumneavoastră la oficiul DSHS local. (Romanian)

Вы можете получить эту брошюру на своём языке в своём местном офисе DSHS.(Russian)

O lo'o maua le tusi lea i lau gagana i le ofisa o le Welfare (DSHS). (Samoan)

Ovaj pamflet je dostupan i na vašem jeziku u vašem mjesnom DSHS uredu. (Serbo-Croatian)

Waraaqahani waxaad ka helikartaa xafiiska Walfeerka, DSHS, ee kuu dhow, iyaga oo ku qorran afgaaga. (Somali)

Ang pamphlet na ito ay nakasulat rin sa Tagalog at makukuha sa tanggapan ng DSHS na pinakamalapit sa inyo. (Tagalog)

እዚ መጽሔት እዚ ብቋንቋኹም ኣብ ከባቢኹም ዝርከብ ቤት ጽሕፈት ዌልፈር ይርከብ (Tigrigna)

Ви можете одержати цю брошуру на своїй мові в своєму місцевому офісі DSHS.(Ukrainian)

Tập sơ liệu này hiện có bằng ngôn ngữ của quí vị tại văn phòng DSHS địa phương.(Vietnamese)

USDA គឺជាអ្នកផ្តល់សេវា និងនិយោជកឱកាសស្មើគ្នា។

©2021 FIS. រក្សាសិទ្ធិគ្រប់យ៉ាង។

Washington State Department of Social & Health Services

*Transforming lives*

DSHS 22-310 CA (Rev. 09/21) Cambodian

# ដោយប្រើកាត Quest EBT វ៉ាស៊ីនតោន




**ការព្រមានការផាកពិន័យ ៖**

**វាគឺខុសច្បាប់ក្នុងការលក់ ឬប៉ុនប៉ងលក់កាត EBT ឬផ្លាស់ប្តូរ ឬប៉ុនប៉ងផ្លាស់ប្តូរអត្ថប្រយោជន៍អាហារចំពោះអ្វីដែលមានតម្លៃដូចជាប្រាក់ ថ្នាំញៀន អាវុធ ឬអ្វីផ្សេងក្រៅពីអាហារដែលមានសិទ្ធិពីអ្នកលក់រាយដែលបានផ្តល់សិទ្ធិ ការប្រើដោយខុសចេតនាអាចបណ្តាលឱ្យលែងមានសិទ្ធិ ផាក និង សកម្មភាពស្របច្បាប់ រួមទាំងការកាត់ទោសព្រហ្មទណ្ឌ។**

សម្រាប់ព័ត៌មានគណនី ចូលទៅ
**www.ebtedge.com**
ឬប្រើកម្មវិធីចល័ត *ebtEDGE*

ឬទូរសព្ទទៅលេខ

## សេវាអតិថិជន

**888-328-9271**
**711 (TTY State Relay)**
**800-833-6385 (Telebraille)**